## ផ្នែក ខ

# ការធ្វើសកម្មភាព



# ២៧ មេរៀនទី២៧ ÷ ការចែករំលែកអ្វីដែលអ្នកចេះជាមួយអ្នកដទៃ

**ទស្សនៈ**

**គោលបំណង**

អ្នកចូលរួម នឹងពិចារណាអំពីមធ្យោបាយនានា ដែលគេអាចចែករំលែកចំណេះ ដឹងដឹងថ្មីអំពីការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ហើយនឹងត្រូវបានណែនាំឲ្យស្គាល់ពីស្បនទាននៃព្រឹត្តិការណ៍នៃសកម្មភាពសម្រាប់សហគមន៍។ អ្នកចូលរួមក៏នឹងឲ្យធ្វើតេស្តក្រោយបញ្ចប់វគ្គផងដែរដែលនឹងត្រូវប្រៀបធៀបជាមួយនឹងការធ្វើតេស្តមុនដើម្បីកំណត់អំពីអ្វីដែលអ្នកចូលរួមបាន សិក្សា ក្នុងអំឡុងពេលនៃវគ្គបណ្ដុះបណ្ដាលនេះ។

**ពេលវេលា**

៧៥ នាទី

**សម្ភារៈ**

- ក្រដាសផ្ទាំងធំ
- ថតចម្លងនូវទម្រង់ពីការឯកភាព លើសកម្មភាពសម្រាប់សហគមន៍ដល់អ្នកចូលរួមម្នាក់ៗ (ទម្រង់នេះមាននៅទំព័រទី ៥ នៃឯកសារកម្រងនេះ)
- ច្បាប់ថតចម្លងនៃ " នេ២៧កៈ ការធ្វើតេស្តក្រោយបញ្ចប់វគ្គ" សម្រាប់អ្នកចូលរួមទាំងអស់គ្នា
- ច្បាប់ថតចម្លងនៃ "ន ២៧ខៈ ទម្រង់អំពីការឯកភាពលើសកម្មភាពសម្រាប់សហគមន៍"

**សេចក្ដីផ្ដើម**

**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចតៗគ្នានូវបញ្ជីចុះហត្ថលេខាវត្តមាន។

**សកម្មភាពមុនចាប់ផ្ដើម**

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំល្បែងថាមពលនៅក្នុងតារាង។

**រំឭកមេរៀន**

តើលេខទូរស័ព្ទសម្រាប់គ្រាអាសន្ន ក្នុងប្រទេសរបស់អ្នកគឺលេខប៉ុន្មានខ្លះ? (ប្រសិនបើ អ្នកចូលរួមច្រឡំ អនុវត្តឡើងវិញ នូវដំណើរការកាលពីមេរៀនមុនដែលក្រុមទាំងមូលបានផ្លាស់ប្ដូរលេខជាមួយគ្នា)។

## ចំណេះដឹងអំពីការជួញដូរ

ពន្យល់ថា វគ្គបណ្ដុះបណ្ដាលនេះមាននិយាយអំពីព័ត៌មានជាច្រើនអំពីការជួញដូរ។ ឲ្យអ្នកចូលរួមផ្ដល់ ជាឧទាហរណ៍អំពីប្រធានបទដែលគេបានរៀនរួច។ បន្ថែមឧទាហរណ៍ខាងក្រោម ប្រសិនបើគេមិនទាន់បានលើកឡើងនៅឡើយ។ សរសេរឧទាហរណ៍ទាំងនេះនៅលើក្រដាសផ្ទាំងធំ

- និយមន័យនៃ ការជួញដូរមនុស្ស
- និយមន័យនៃការជួញដូរកុមារ
- ភាពខុសគ្នារវាងការជួញដូរ និងការរត់ពន្ធខុសច្បាប់
- ការជួញដូរមនុស្សសម្រាប់គោលបំណងបម្រើសេវាផ្លូវភេទ រួមទាំង CSEC (ការប្រកបរបរអាជីវកម្មផ្លូវភេទលើកុមារ) និងការធ្វើការងារជាស្ត្រីពេស្យាផងដែរ
- ការជួញដូរសម្រាប់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម

- ការជួញដូរពលកម្មកុមារ
- ការជួញដូរមនុស្សអាចកើតមានគ្រប់ទីកន្លែង
- ល្បិចទូទៅដែលប្រើដោយអ្នកជួញដូរ
- ទំនាក់ទំនងរវាងការជួញដូរមនុស្ស និងការប្រើប្រាស់គ្រឿងញៀន
- ទំនាក់ទំនងរវាងការជួញដូរមនុស្ស និងយែនឌ័រ
- របៀបរៀបចំដើម្បីត្រៀមធ្វើចំណាកស្រុកដោយសុវត្ថិភាព
- ការរក្សាខ្លួនឲ្យមានសុត្ថិភាពអំឡុងពេលកំពុងធ្វើដំណើរ
- របៀបរក្សាខ្លួនឲ្យមានសុវត្ថិភាពបន្ទាប់ពីទៅដល់គោលដៅនៃការធ្វើចំណាកស្រុក
- តើត្រូវធ្វើអ្វីខ្លះប្រសិនបើអ្នកត្រូវបានជួញដូរ។

ប្រាប់ទៅអ្នកចូលរួមថា មេរៀននេះនិយាយអំពីមធ្យោបាយផ្សេងៗគ្នានៃការចែករំលែកព័ត៌មានជាមួយអ្នកដទៃ។

## ការចែករំលែកចំណេះដឹង តាមរយៈការជជែកគ្នា

សួរថា "តើអ្នកគិតថា ព័ត៌មាននេះអាចជួយអ្នកផ្សេងបានផងដែរ ឬទេ?" ឲ្យអ្នកចូលរួម ហៅឈ្មោះ អ្នកផ្សេង ដែលអាចទទួលអត្ថប្រយោជន៍ពីការរៀនព័ត៌មាននេះ។ ធ្វើបញ្ជីមួយ ពេលគេនិយាយ។ ឲ្យគេគិតថា តើព័ត៌មាននេះអាចចែករំលែកបានជាមួយនឹងមិត្តភក្តិ ឪពុកម្តាយរបស់គេ អាជ្ញាធរមូលដ្ឋាន ឬអ្នកដែលធ្វើការងារនៅសាលារៀនរបស់គេ។

ជាកិច្ចចាប់ផ្តើមពន្យល់ថា មធ្យោបាយសាមញ្ញបំផុតគឺតាមរយៈការជជែកជាមួយអ្នកដទៃអំពីអ្វីដែលគេចេះដឹង។

ពេលនេះ ឲ្យពួកគេមើលតារាងឈ្មោះមនុស្សដែលអាចទទួលអត្ថប្រយោជន៍ពីការរៀនលើព័ត៌មានទាំងនេះ។ តើឈ្មោះនរណាខ្លះនៅក្នុងតារាងនេះ ដែលគេតែងតែជជែកជាមួយ? (អ្នកចូលរួមប្រហែលជានិយាយថា គេជជែកជាមួយឪពុកម្តាយរបស់គេ និងមិត្តភក្តិរបស់គេ និង អាចជាលោកគ្រូ/អ្នកគ្រូរបស់គេផងដែរ)។

ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួនអំពីយុវវ័យដែលគិតចំពោះអ្នកដទៃ អំពីការជួញដូរ (អានឲ្យឮទៅកាន់អ្នកចូលរួម) ៖

"នៅពេលដែលមីងរបស់ខ្ញុំបានមកលេងហើយបានប្រាប់ខ្ញុំថា កូនស្រីរបស់គាត់បានធ្វើចំណាក់ស្រុកទៅប្រទេសក្រៅ ខ្ញុំបានប្រាប់គាត់អំពីអ្វីដែលខ្ញុំបានរៀនចេះពី SNYC ។ ខ្ញុំបានបង្ហាញពីតារាង ត្រួតពិនិត្យរបស់ខ្ញុំសំរាប់ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។"

"ខ្ញុំមានមិត្តម្នាក់ដែលឈប់មករៀន។ នៅពេលខ្ញុំទៅលេងផ្ទះនាង នាងបាននិយាយ ប្រាប់ខ្ញុំថា នាងបានឈប់រៀនដោយសារតែចង់ធ្វើការងារ។ ខ្ញុំបានប្រាប់នាងថា នាងអាចនិង ទទួលបានការងារល្អប្រសើរធ្វើប្រសិនបើនាងរៀនឲ្យចប់សិន ហើយខ្ញុំបានជួយបញ្ចុះបញ្ចូលឪពុកម្តាយរបស់នាងដើម្បីអនុញ្ញាតិឲ្យនាងត្រឡប់ទៅសាលារៀនវិញ។"

"ខ្ញុំបានប្រាប់មិត្តស្រីៗនៅក្នុងថ្នាក់រៀនរបស់ខ្ញុំអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។"

"ខ្ញុំមានអាយុ១៨ឆ្នាំ។ឪពុកម្តាយរបស់ខ្ញុំបានប្រាប់ថាពួកគាត់គិតថាខ្ញុំនឹងមានអនាគតល្អប្រសិន

បើខ្ញុំរកការងារធ្វើនៅប្រទេសក្រៅ។ ខ្ញុំបានចែករំលែកព័ត៌មានដែលខ្ញុំបានរៀនពី SNYC ជាមួយពួកគាត់ ដូច្នេះយើងអាចធ្វើផែនការរួមគ្នាដើម្បីធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ "ក្មេងប្រុសម្នាក់រៀននៅថ្នាក់ជាមួយខ្ញុំបានប្រាប់ថា គេនឹងទៅទីក្រុងដើម្បីរកការងារធ្វើ។ ខ្ញុំបានប្រាប់គេថា ឯងត្រូវតែរៀបចំផែនការសិនមុននឹងចេញទៅហើយ ត្រូវធ្វើដំណើរដោយមានប្រាក់គ្រប់គ្រាន់ដើម្បីត្រឡប់មកផ្ទះវិញ ប្រសិនបើគេមិនអាចរកការងារបានធ្វើនោះ ហើយអ្នកត្រូវតែទុកឯកសារថតចម្លងមួយច្បាប់នៅគ្រួសាររបស់អ្នក ហើយអ្នកចាំបាច់ត្រូវមានលេខសម្រាប់គ្រាអាសន្ន។"

## ការចែករំលែកចំណេះដឹងតាមរយៈសកម្មភាពសម្រាប់សហគមន៍

ពន្យល់ថា ប៉ុន្មានមេរៀនបន្ទាប់ទៀត SNYC នឹងធ្វើការងារជាក្រុមដើម្បីចាត់វិធានការជួយដល់សហគមន៍។ អ្នកចូលរួមនឹងកំណត់ឃើញអ្វីដែលគេចង់ធ្វើការកែលម្អនៅក្នុងសហគមន៍របស់គេ និងគិតអំពីអ្វីដែលគេអាចធ្វើបានដើម្បីជួយ។ ការចូលរួមក្នុងគម្រោងនេះ គឺជាការស្ម័គ្រចិត្ត។ សមាជិកក្លឹប មិនចាំបាច់ចូលរួមទេ ប្រសិនបើគេមិនចង់ចូលរួម។ ប្រសិនបើគេចង់ពិភាក្សាថា ត្រូវចូលរួម ឬយ៉ាងណានោះ ប្រាប់ទៅគេថា អ្នកសម្របសម្រួលនឹងនៅក្នុងបន្ទប់នេះក្រោយចប់មេរៀន។

ពន្យល់ថាសកម្មភាពសហគមន៍ដែលក្រុមយើងធ្វើនោះ អាចមានទំហំធំ ឬតូច។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួននៃសកម្មភាពសហគមន៍ ៖

- ការសរសេរពាក្យថ្មីឲ្យទៅជាចង្វាក់ភ្លេងបែបប្រពៃណីមួយ។ ពាក្យពេចន៍រៀបរាប់អំពីរបៀបធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ ចែករំលែកនូវចម្រៀងនេះជាមួយនឹងកុមារដទៃទៀត នៅសាលារៀនរបស់អ្នក។
- បង្កើតផ្ទាំងរូបភាពដែលបង្ហាញពីចំណេះដឹងថ្មីរបស់អ្នកដល់សហគមន៍។ ឧទាហរណ៍អ្នកត្រូវសុំការអនុញ្ញាតិពីសាលា ដើម្បីព្យួររូបនេះ ដែលនិយាយពីរបៀបធ្វើចំណាកស្រុកសុវត្ថិភាព
- បង្កើតជា ខិតប័ណ្ណដែលចែករំលែកពីចំណេះដឹងថ្មីរបស់អ្នកជាមួយសហគមន៍។ ឧទាហរណ៍ដូចជា អ្នកអាចបង្កើតជាខិតប័ណ្ណដែលនិយាយអំពីល្បិចទូទៅដែលគេប្រើប្រាស់ក្នុងអំឡុងពេលកំពុងធ្វើដំណើរ ហើយសុំការអនុញ្ញាតពីក្រុមហ៊ុនរថយន្ត (និងអាជ្ញាធរ ប្រសិនបើអាច) ដើម្បីចែកចាយខិតប័ណ្ណទាំងនេះទៅឲ្យយុវវ័យដែលកំពុងជិះរថយន្តនោះ។
- រៀបចំបង្កើតការសម្តែងរឿងអំពីហានិភ័យនៃការជួញដូរ និងសម្តែងវានៅក្នុងព្រឹត្តិការណ៍ប្រចាំភូមិ។
- បង្កើតតារាងព័ត៌មានមួយនិយាយអំពីហានិភ័យនៃការជួញដូរ និងចែករំលែកវាជាមួយនឹង អ្នកដែលអាចជួយដល់ជនចំណាកស្រុក ដូចជាអ្នកបើកបររថយន្តក្រុង និងអាជ្ញាធរមូលដ្ឋានជាដើម។
- បង្កើតទំព័រហ្វេសប៊ុកសម្រាប់ នារីកង់ឆ្លាតជាមួយអ្នកចូលរួមពីក្នុងក្រុមដើម្បីឲ្យ ពួកគេអាចរក្សាទំនាក់ទំនងគ្នាបាន និងចែករំលែកបទពិសោធន៍អំពីការធ្វើចំណាកស្រុក ប្រកបដោយសុវត្ថិភាព។ ទំព័រនេះនឹងមានលក្ខណៈជាទំព័រឯកជនមួយដើម្បីឲ្យក្រុមជន មិនស្គាល់មុខអាចចូលរួមបាន។ ជាការសំខាន់គឺត្រូវធានាចំពោះសុវត្ថិភាពរបស់ពួកគេ។ ដើម្បីបង្កើតទំព័រនេះបាន អ្នកចូលរួមអាចនឹងត្រូវការជំនួយពីអ្នកសម្របសម្រួលជាមនុស្សធំដើម្បីឲ្យ ប្រាកដថា វាត្រូវបានបង្កើតឡើងដោយសុវត្ថិភាព។

- សុំការអនុញ្ញាតពីសាលារៀនរបស់អ្នកដើម្បីបង្រៀនអំពីលេខទូរស័ព្ទពេលគ្រាអាសន្នទៅកាន់កុមារគ្រប់រូបនៅក្នុងសាលារៀន និងរៀបចំសកម្មភាពដើម្បីធ្វើព្រឹត្តិការនេះ។
- ចាប់ផ្តើមពីក្រុមយុវជនរបស់អ្នកដើម្បីពិភាក្សាអំពីការជួញដូរ។

ពន្យល់ថា ទាំងនេះគឺគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ ។ អ្នកចូលរួមមិនចាំបាច់ធ្វើតាមរាល់ឧទាហរណ៍ទាំងអស់នេះឡើយ។ អ្នកអាចគិតអំពីគំនិតផ្ទាល់ខ្លួនរបស់អ្នកបាន។ ប៉ុន្តែឧទាហរណ៍ទាំងអស់នេះគឺដើម្បីផ្តល់ឲ្យពួកគេនូវគំនិតអំពីថា តើសកម្មភាពសម្រាប់សហគមន៍នេះ មានទំហំធំ ឬតូចកម្រិតណា ហើយអាចអនុវត្តក្នុងទម្រង់ផ្សេងៗគ្នា។

## ការរៀបចំធ្វើតេស្តក្រោយបញ្ចប់វគ្គ

ការធ្វើតេស្តក្រោយបញ្ចប់វគ្គត្រូវរៀបចំឲ្យបានមុនព្រឹត្តិការណ៍សកម្មភាពសម្រាប់សហគមន៍ក្នុងករណីដែលមានអ្នកចូលរួមដែលមិនចូលរួម។ ពន្យល់ថា វាជាក្តីសង្ឃឹមរបស់អង្គការទស្សនពិភពលោកផងដែលថា យុវវ័យនឹងចេះដឹងបានច្រើនគ្រប់ចំនុចប្រធានបទទាំងនេះ។ ជាថ្មីម្តងទៀត គឺថាវាមានសារៈសំខាន់ណាស់ដែលបរិយាកាសមានភាពរសាយ និងកក់ក្តៅ។ អ្នកចូលរួមត្រូវបានអនុញ្ញាតិឲ្យសួរសំណួរ និងផ្តល់ចម្លើយដោយការធ្វើតម្រាប់តាមអ្នកសម្របសម្រួលប្រសិនបើគេចង់ធ្វើ។

អានអត្ថបទខាងក្រោមឲ្យអ្នកចូលរួមស្តាប់ ។

សូមស្វាគមន៍ យើងនឹងត្រូវបំពេញទម្រង់មួយដើម្បីទទួលបាននូវគំនិតថា តើអ្នកដឹងអំពីប្រធានបទយើងបានសិក្សានៅក្នុងវគ្គបណ្តុះបណ្តាលនេះក្នុងកម្រិតណា។ ទម្រង់នេះ គឺសម្រាប់អង្គការទស្សនពិភពលោក ដើម្បីជួយកែលម្អវគ្គបណ្តុះបណ្តាលរបស់យើងបាន។ ប្រសិនបើ អ្នកចង់ឲ្យអ្នកសម្របសម្រួលអានសំណួរ ហើយអ្នកកត់ចម្លើយនោះ សូមប្រាប់ អ្នកសម្របសម្រួលឲ្យបានដឹង។

ចែកឯកសារថតចម្លង "TS ២៧៖ ការធ្វើតេស្តក្រោយបញ្ចប់វគ្គ" ទៅឲ្យអ្នកចូលរួម ឬអង្គុយជាមួយអ្នកចូលរួមម្តងម្នាក់ៗ អាននិងកត់ចម្លើយ។ ប្រមូលការធ្វើតេស្តក្រោយបញ្ចប់វគ្គដើម្បីប្រៀបធៀប ជាមួយនឹងធ្វើតេស្តមុនវគ្គបណ្តុះបណ្តាលបន្ទាប់ពីគេបានបញ្ចប់។

## កំណាត់ហេតុ

ឲ្យអ្នកចូលរួមសរសេរ អំពីមធ្យោបាយនានាដែលគេអាចចែករំលែកចំណេះដឹងថ្មីរបស់គេជាមួយអ្នកផ្សេង។ សុំឲ្យគេព្យាយាមគិតពីពេលវេលាដែលគេអាចជជែកជាមួយអ្នកដទៃនៅក្នុងសហគមន៍របស់គេ និងសកម្មភាពសម្រាប់សហគមន៍ ដែលអាចធ្វើទៅបានដោយការជជែកជាក្រុម។

### សង្ខេបមេរៀន

- អ្នកអាចជួយអ្នកដទៃ ពីការជួញដូរដោយការចែករំលែកព័ត៌មាន ដែលអ្នកបានរៀន នៅក្នុងសៀវភៅកម្រងនេះ
- មធ្យោបាយមួយក្នុងការចែករំលែកព័ត៌មាន គឺការជជែកអំពីវា។

- មធ្យោបាយផ្សេងមួយទៀត គឺតាមរយៈសកម្មភាពសម្រាប់សហគមន៍ដែលយើងនឹងធ្វើរួមគ្នា នៅក្នុងប៉ុន្មានមេរៀនបន្ទាប់ទៀត។
- អ្នកមិនចាំបាច់ត្រូវចូលរួមនៅក្នុងសកម្មភាពសម្រាប់សហគមន៍ទេប្រសិនបើអ្នកមិនចង់។

## ការបិទបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ ឬផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានចូលរួម។ បន្ទាប់មកប្រាប់គេថា គេទទួលបានផ្កាយមួយទៀតសម្រាប់មេរៀននេះ។

ចែកឯកសារថតចម្លងនៃ “IS ២៧ខ៖ ទម្រង់អំពីការឯកភាពលើសកម្មភាពសម្រាប់សហគមន៍ និងពន្យល់ថា វាជាការស្ម័គ្រចិត្ត។ ឲ្យអ្នកចូលរួមប្រគល់ទំរង់នេះឪពុកម្តាយ ឬអ្នកផ្តល់ការថែទាំរបស់គេចុះហត្ថលេខាលើទម្រង់នេះ។ ពន្យល់ថា គេត្រូវតែមានការឯកភាពដើម្បីចូលរួមក្នុងព្រឹត្តិការណ៍ អំពីសកម្មភាពសម្រាប់សហគមន៍នេះ ហើយគេត្រូវតែនាំយកមកជាមួយនូវ ទម្រង់ដែលមានចុះហត្ថលេខាសម្រាប់មេរៀនបន្ទាប់ទៀត។ (ប្រសិនបើអ្នកបារម្ភថា អ្នកចូលរួមមិនអាចធ្វើបែបនេះបាននោះ ចូររកវិធីសាស្រ្តផ្សេងទៀតដើម្បីឲ្យ ឪពុកម្តាយ /អ្នកផ្តល់ការថែទាំ ឲ្យបំពេញទម្រង់ស្តីពីការឯកភាពនេះ)។

## បន្ទាប់ពីមេរៀន ៖ ប្រៀបធៀប ការធ្វើតេស្តមុនបណ្តុះបណ្តាល និងការធ្វើតេស្តក្រោយការបណ្តុះបណ្តាល

នៅពេលដែលកុមារបានបំពេញចប់សព្វគ្រប់នូវការធ្វើតេស្តក្រោយបណ្តុះបណ្តាល សូមធ្វើការប្រៀបធៀបជាមួយនឹងការធ្វើតេស្តមុនបណ្តុះបណ្តាល។ ប្រៀបធៀបចម្លើយដើម្បីវាយតម្លៃថា តើអ្នកចូលរួមរៀនបានអ្វីខ្លះ។ វាយតម្លៃដូចខាងក្រោម ៖

- ប្រែប្រួលចំណេះដឹង
- ប្រែប្រួលជំនាញ
- ប្រែប្រួលអាកប្បកិរិយា

អ្នកសម្របសម្រួលត្រូវប្រើប្រាស់ព័ត៌មានដែលគេទទួលបានពីការធ្វើតេស្តមុន និងក្រោយការបណ្តុះបណ្តាលដើម្បី

- កែតម្រូវមធ្យោបាយដែលគេបង្រៀនការបណ្តុះបណ្តាលនេះនៅថ្ងៃក្រោយ។ ឧទាហរណ៍ថា ប្រសិនបើអ្នកចូលរួមមិនយល់ប្រធានបទណាមួយ ត្រូវចំណាយពេលឲ្យច្រើនបន្តិចដើម្បីបង្រៀនមេរៀននោះនៅពេលក្រោយ។
- ជូនដំណឹងទៅអង្គការ ទស្សនពិភពលោកអំពីចំណុចខ្លាំង និងចណុចខ្សោយនៅក្នុងវគ្គបណ្តុះបណ្តាលនេះដើម្បីអាចកែលម្អ និងកែសម្រួលវគ្គបណ្តុះបណ្តាលនេះ។

# IS ២៧ក ÷ តេស្តក្រោយវគ្គបណ្តុះបណ្តាល ២៧

ឈ្មោះ ៖ .......................................................................................
កាលបរិច្ឆេទ៖ ..................................................................................
ទីតាំងក្លិប ៖ ...................................................................................

1. តើការជួញដូរមនុស្ស មានអត្ថន័យយ៉ាងដូចម្តេច?
   a. ការនាំនរណាម្នាក់ឆ្លងដែនទៅកាន់ប្រទេសដទៃ
   b. ការប្រើល្បិច ឬបង្ខំមនុស្សឲ្យធ្លាក់ចូលទៅក្នុងការកេងប្រវ័ញ្ចកំលាំងពលកម្មការងារ
   c. លក់សត្វដែលកាចសាហាវ ដើម្បីបានអត្ថប្រយោជន៍
   d. លក់អាវុធ និងថ្នាំញៀនខុសច្បាប់

2. តើអំពើជួញដូរមនុស្ស និងអំពើរត់ពន្ធមនុស្សខុសគ្នាយ៉ាងដូចម្តេច?
   a. ការរត់ពន្ធ គឺគេជួលនរណាម្នាក់ឲ្យនាំឆ្លងដែនខុសច្បាប់ ប៉ុន្តែមានជម្រើសក្នុងការសម្រេចចិត្តធ្វើការងារ
   b. សំដៅលើជនដែលត្រូវបានគេជួញដូរ ហើយគ្មានជម្រើសថា តើពួកគេធ្វើអ្វីនៅពេលដែលពួកគេទៅដល់ទីកន្លែង
   c. ការរត់ពន្ធមនុស្សសំដៅលើការនាំឆ្លងដែនទៅក្រៅប្រទេស ឯការជួញដូរមនុស្សសំដៅលើការចរាចរក្នុងប្រទេស
   d. ជម្រើស "a" និង "b" ខាងលើ

3. តើការជួញដូរមនុស្ស អាចកើតមានឡើងនៅទីណាខ្លះ?
   a. កើតមានឡើងតែនៅកន្លែងដែលអ្នករស់នៅតែប៉ុណ្ណោះ
   b. កើតមានឡើងតែនៅកន្លែងទីប្រជុំជនជិតព្រំដែនតែប៉ុណ្ណោះ
   c. កើតមានឡើងនៅទីក្រុងធំៗតែប៉ុណ្ណោះ
   d. កើតមានឡើងនៅគ្រប់កន្លែងទាំងអស់ហ្នឹង

4. តើឈ្មួញជួញដូរមនុស្សប្រើល្បិចអ្វីខ្លះ ដើម្បីជួញដូរមនុស្ស ?
   a. ដើរតួជាភ្នាក់ងារជ្រើសរើសពលករស្របច្បាប់
   b. សន្យាផ្តល់ និងជួយរកការងារទទួលបានប្រាក់ខែខ្ពស់
   c. ជនដែលប្រមូលយកឯកសារស្របច្បាប់របស់ពលកររក្សាទុក( លិខិតឆ្លងដែន )
   d. ទាំងអស់ខាងលើ

5. ជំនាញក្នុងការនិយាយមានអត្ថន័យយ៉ាងដូចម្តេច ?
   a. និយាយបានទាំងអស់ និងគ្រប់ពេលដែលអ្នកចង់
   b. និយាយថា "បាទ" ទៅកាន់អ្នករាល់គ្នា បើទោះបីជាមិនចង់ធ្វើក៏ដោយ
   c. និយាយពាក្យដែលមានអំណះអំណាងច្បាស់លាស់ ហើយសមរម្យ
   d. គ្មានចម្លើយដូចខាងលើ

6. សូមមេត្តាជួយពិពណ៌នាពីជំនាញក្នុងការស្តាប់ មានអត្ថន័យយ៉ាងដូចម្តេច ?
   a. កំពុងតែនិយាយជាមួយអ្នក ប៉ុន្តែគិតរឿងផ្សេង
   b. មិនយល់ទាល់តែសោះ ប៉ុន្តែធ្វើជាយល់ច្បាស់
   c. ស្តាប់យ៉ាងយកចិត្តទុកដាក់បំផុត ហើយសំយោគនៅអ្វីដែលគេបាននិយាយ ដើម្បីបានយល់កាន់តែច្បាស់ថែមទៀត
   d. មិនសួរសំណួរអ្វីទាំងអស់ ទោះបីជាចង់ដឹងរឿងបន្ថែមក៏ដោយ

7. សូមអ្នកជ្រើសរើសចំលើយពីរបៀបនៃការពិចារណា មុនពេលធ្វើការសម្រេចចិត្ត ?
   a. ធ្វើតាមគំនិតរបស់មិត្ត គឺល្អណាស់
   b. ធ្វើតាមតែគំនិតរបស់ឪពុកម្តាយ គឺល្អណាស់
   c. ស្វែងរកព័ត៌មានឲ្យបានច្រើន ហើយប្រឹក្សាជាមួយបុគ្គលដែលអ្នកទុកចិត្ត មុនពេលធ្វើការសម្រេចចិត្ត
   d. គ្មានចម្លើយដូចខាងលើ

8. សូមជួយពិពណ៌នាថា តើ ថ្នាំញៀន អាចប៉ះពាល់អ្វីខ្លះដល់មនុស្ស ?
   a. ឆ្លងជម្ងឺ អេដស៍ និងជម្ងឺផ្សេងៗទៀត  នៅពេលចាក់ថ្នាំញៀន ដោយប្រើម្ជុលរួមគ្នា
   b. សេពគ្រឿងញៀន ធ្វើឲ្យអ្នកស្ថិតក្នុងភាពប្រឈមមុខនឹងគ្រោះថ្នាក់
   c. សេពគ្រឿងញៀន ជួយឲ្យការចងចាំបានល្អ
   d. ជម្រើស "a" និង  "b" ខាងលើ

9. តើសកម្មភាពអ្វីខ្លះ ដែលអាចជួយអ្នកមានសុវត្ថិភាពពេលអ្នកទៅធ្វើការនៅប្រទេសដទៃ ?
   a. ដាក់លិខិតឆ្លងដែន  និងទិដ្ឋាការធ្វើការជាប់ខ្លួន នៅពេលទៅធ្វើការក្នុងប្រទេសដទៃ
   b. យកឯកសារសំខាន់នានារបស់អ្នកតាមខ្លួន នៅពេលអ្នកត្រលប់មកផ្ទះវិញ
   c. យកថវិការឲ្យបានគ្រប់គ្រាន់សម្រាប់ទូទាត់សោហ៊ុយធ្វើដំណើរនៅពេលត្រឡប់មកផ្ទះ
   d. ចម្លើយទាំងអស់ខាងលើ

10. នៅក្នុងប្រទេសរបស់អ្នក តើប្រព័ន្ធទូរស័ព្ទមួយណា ដែលអ្នកត្រូវទំនាក់ទំនងជាបន្ទាន់នៅពេលមានគ្រោះថ្នាក់ ឬមានការជួញដូរមនុស្សកើតឡើង ?
   a. (844) 3936 6633
   b. 1300

c. (856) 20 5483 8969

d. (95) 67 412 555

e. (855) 017 276 222

f. 12333

11. នៅក្នុងប្រទេសទទួល/ប្រទេសគោលដៅ តើប្រព័ន្ធទូរស័ព្ទមួយណា ដែលអ្នកត្រូវទំនាក់ទំនងជាបន្ទាន់ នៅពេលមានគ្រោះថ្នាក់ ឬមានការជួយជួរមនុស្សកើតឡើង?

a. (844) 3936 6633

b. 1300

c. (856) 20 5483 8969

d. (95) 67 412 555

e. (855) 017 276 222

f. 12333

12. តើលិខិតឆ្លងដែនជាអ្វី?

a. ជាលិខិតអនុញ្ញាតិឲ្យចេញ និងចូលប្រទេសរបស់ខ្លួន ដែលចេញដោយរដ្ឋាភិបាលនៃប្រទេសរបស់អ្នក

b. ជាសន្លឹកក្រដាសពិសេសមួយ ដែលអនុញ្ញាតិឲ្យអ្នកធ្វើដំណើរទៅកាន់ខេត្តផ្សេងៗបាន

c. ជាឯកសារចុះហត្ថលេខា ដោយមេភូមិក្នុងភូមិរបស់អ្នក

d. គ្មានចម្លើយដូចខាងលើ

13. តើទិដ្ឋាការជាអ្វី?

a. ជាសំបុត្រសម្រាប់ទិញម្ហូបអាហារ

b. ជាត្រា ឬក៏តែមបិតលើលិខិតឆ្លងដែនអាចឲ្យអ្នកឆ្លងទៅប្រទេសផ្សេងបានដោយស្របច្បាប់

c. ស្នាមត្រាក្នុងសំបុត្រកំណើតរបស់អ្នក

d. គ្មានចម្លើយដូចខាងលើ

14. តើទិដ្ឋាការធ្វើការ និងទិដ្ឋាការធ្វើដំណើរកំសាន្ត ខុសគ្នាយ៉ាងដូចម្តេច?

a. ទិដ្ឋាការធ្វើការ អ្នកអាចធ្វើការនៅប្រទេសដទៃបានដោយស្របច្បាប់ ឯទិដ្ឋាការធ្វើដំណើរកំសាន្តអនុញ្ញាតិបានតែដំណើរកំសាន្តប៉ុណ្ណោះ មិនអាចធ្វើការបានទេ

b. ទិដ្ឋាការធ្វើការអនុញ្ញាតិឲ្យអ្នកធ្វើការនៅឯផ្ទះ ឯទិដ្ឋាការធ្វើដំណើរកំសាន្តអនុញ្ញាតិឲ្យ អ្នកធ្វើដំណើរទៅកាន់ខេត្តផ្សេងៗទៀតដើម្បីកំសាន្តសប្បាយ

c. ទិដ្ឋាការធ្វើការអនុញ្ញាតិឲ្យអ្នកធ្វើដំណើរទៅកាន់ប្រទេសមួយទៀត ដើម្បីកំសាន្តសប្បាយ ឯទិដ្ឋាការធ្វើដំណើរកំសាន្តអនុញ្ញាតិឲ្យអ្នកធ្វើដំណើរកំសាន្តមានរយៈពេលយូរ

d. គ្មានចម្លើយខាងលើ

15.ប្រសិនបើអ្នកមានបំណងធ្វើចំណាក់ស្រុក ជំហានអ្វីខ្លះដែលជួយអោយអ្នកចំណាកស្រុក ប្រកដដោយសុវត្ថិភាព?

a. ទៅដោយមិនចាំបាច់សួរនរណាទាំងអស់

b. ប្រាប់ភ្លាមទៅភ្លាម

c. ទៅតាមមិត្តភក្តិប្រាប់ដោយមិនបានពិភាក្សាជាមួយឪពុកម្តាយ

d. ស្វែងរកព័ត៌មានអោយបានច្រើន ស្តីពីទីកន្លែង ការធ្វើដំណើរ និងប្រភេទនៃការងារមុនពេលធ្វើចំណាកស្រុក

16.តើអ្នកធ្លាប់រៀបចំអ្វីខ្លះ ដើម្បីជួយដល់យុវជនក្នុងសហគមន៍របស់អ្នកដែរ ឬទេ? ប្រសិនបើបាទ សូមជួយរៀបរាប់?

□បាទ/ចាស+ □ទេ

ឯកសារយោងរបស់អ្នកសម្របសម្រួលប៉ុណ្ណោះ

អ្នកចូលរួមប្រហែលជា ផ្តល់ចម្លើយដោយប្រើពាក្យពេចន៍ផ្សេងនៅពេលដែលពួកគេផ្តល់ចម្លើយរបស់គេហើយកត្តានេះមិនជាបញ្ហាអ្វីទេ។ រឿងដែលសំខាន់គឺគេយល់បានអំពីអត្ថន័យនៅពីក្រោយពាក្យ។

មិនត្រូវចែកចាយលទ្ធផលនៃការធ្វើតេស្តនេះទៅ ឲ្យអ្នកចូលរួមទេ។ នេះមិនមែនជាការធ្វើតេស្តនៅ សាលារៀនទេ។ អ្នកចូលរួមនឹងមិនទទួលបានចំណាត់ថ្នាក់ទេ ។ ប្រសិនបើអ្នកប្រាប់អ្នកចូលរួមណាម្នាក់ថា គេធ្វើបានល្អណាស់នោះ នៅប្រហែលជាអាចធ្វើឲ្យអ្នកចូលរួមផ្សេងទៀតយល់ថា គេធ្វើមិនបានល្អ ហើយឈប់មកចូលរួមក្នុងក្លិបបន្តទៅទៀត។ អ្នកចូលរួមដែលមិនយល់អាចជាអ្នកដែលយើងត្រូវជួយគេឲ្យបានច្រើនជាងគេបន្តិច។

### ១. តើការជួញដូរមនុស្សមានន័យដូចម្តេច? (ពីមេរៀនទី ៣)

- ការជួញដូរមនុស្ស គឺជាការឆបោក ឬបង្ខិតបង្ខំមនុស្សឲ្យធ្លាក់ចូលទៅក្នុងទម្រង់ការងារបែបកេងប្រវ័ញ្ច ជនរងគ្រោះនៃអំពើជួញដូរពិបាកក្នុងការគេចចេញ។ ការជួញដូរមនុស្សជាធម្មតាគឺទាក់ទងនឹងការយកជនរងគ្រោះ ចេញពីកន្លែងដែលគេរស់នៅទៅកាន់កន្លែងផ្សេងទៀតដោយការការបង្ខំ ដើម្បីកេងប្រវ័ញ្ច។ ប៉ុន្តែ មានអ្នកខ្លះត្រូវបានគេជួញដូរដោយមិនបាច់ ផ្លាស់ទីកន្លែងផងដែរ។

### ២. តើអ្វីជាភាពខុសគ្នារវាងការជួញដូរ និងការរត់ពន្ធមនុស្ស (ពីមេរៀនទី ៣)

- ការជួញដូរមនុស្ស ខុសពីការរត់ពន្ធមនុស្ស។ នៅពេលមនុស្សត្រូវបានគេរត់ពន្ធ គឺគេជួលឲ្យមនុស្សម្នាក់ផ្សេងទៀតឲ្យនាំពួកគេឆ្លងកាត់ព្រំដែនដោយខុសច្បាប់។ បើទោះបីជាជនដែលត្រូវគេរត់ពន្ធត្រូវបានគេផ្តល់ប្រាក់ឲ្យដើម្បីធ្វើដំណើរ ហើយអាចនឹងនៅជាប់បំណុលក្រោយពីធ្វើដំណើររួចក៏ដោយ គឺពួកគេនឹងមានសេរីភាពជាធម្មតានៅពេលដែលទៅដល់គោលដៅ។ អ្នកដែលត្រូវគេជួញដូរ មិនមានសេរីភាពទេ។ មនុស្សសុខចិត្តឲ្យគេរត់ពន្ធខុសច្បាប់។

### ៣. តើការជួញដូរមនុស្សកើតមានឡើងនៅកន្លែងណា? (ពីមេរៀនទី ៤)

- ការជួញដូរមនុស្សកើតមានគ្រប់ទីកន្លែង - នៅផ្ទះ ពេលធ្វើដំណើរ ឬនៅកន្លែងគោលដៅ។ ជនម្នាក់មិនចាំបាច់ទាល់តែផ្លាស់ទីកន្លែងបានត្រូវគេជួញដូរនោះទេ។

### ៤. តើអ្វីខ្លះជាល្បិចទូទៅរបស់អ្នកជួញដូរមនុស្ស?

- ជំនាញទំនាក់ទំនងល្អគឺនៅពេលដែលអ្នកប្រើប្រាស់ទំនាក់ទំនងបែបហ្មត់ចត់ - និយាយដោយគ្មានភាពក្រោវក្រោធ ឬទន់ជ្រាយ។ នៅក្នុងទំនាក់ទំនងល្អ អ្នកនិយាយ ដោយគួរសមដើម្បីការពារខ្លួនអ្នក។

### ៥. តើអ្នកអាចរៀបរាប់ពីជំនាញក្នុងការនិយាយបានល្អដែរ ឬទេ?

- ជំនាញក្នុងការនិយាយបានល្អ គឺនៅពេលដែលអ្នកនិយាយអ្វីដែលអ្នកចង់និយាយ ហើយមាន ការគួរសម។ អ្នកអាចប្រើប្រាស់ជំនាញទំនាក់ទំនងបែបហ្មត់ចត់ ជំនួសឲ្យជំនាញទំនាក់ទំនងបែបក្រេវក្រោធ ឬទន់ជ្រាយ។ អ្នកនិយាយការពារខ្លួនអ្នកដោយគួរសម។

### ៦ . តើអ្នកអាចរៀបរាប់បានទេថា អ្វីខ្លះជាជំនាញក្នុងការស្តាប់ បានល្អ?

- គិតអំពីអ្វីដែលគេកំពុងនិយាយ។
- សួរអំពីអ្វីដែលអ្នកមិនយល់។
- គិតអំពីអ្វីដែលអ្នកចង់ដឹងបន្ថែម និងសួរសំណួរទៅតាមនោះ។
- និយាយឡើងវិញអំពីអ្វីគេទើបនិយាយ។

### ៧.តើអ្នកគិតថា អ្នកអាចប្រើប្រាស់ជំនាញក្នុងការទំនាក់ទំនងល្អដែលអ្នកបានរៀននៅក្នុងក្លិបនេះនៅក្នុងជីវិតពិតរបស់អ្នកបានដែរ ឬទេ? ប្រសិនបើអាច សូមរៀបរាប់ពីរបៀប។

- ប្រសិនបើអ្នកចូលរួមប្រើប្រាស់ជំនាញទាំងនេះ គេអាចរៀបរាប់បាននៅត្រង់នេះ។

### ៨. តើអ្វីខ្លះជាល្បិចទូទៅរបស់អ្នកជួញដូរមនុស្ស?

- អ្នកជួញដូរធ្វើពុតជាអ្នកឈ្មួញកណ្តាលស្របច្បាប់ម្នាក់។
- អ្នកជួញដូរធ្វើពុតជាមិត្តភ័ក្តិម្នាក់ ឬធ្វើជាចង់ជួយ។
- អ្នកជួញដូរផ្តល់ប្រាក់ខែឲ្យខ្ពស់។ ជាញឹកញាប់គឺប្រាក់ខែខ្ពស់ខុសពីធម្មតា។
- អ្នកជួញដូរឲ្យជនចំណាក ស្រុកបង់ប្រាក់ចុះឈ្មោះចេញថ្លៃធ្វើដំណើរឲ្យជនចំណាកស្រុក ឬឲ្យប្រាក់ជនរងគ្រោះខ្ចីដើម្បីឲ្យប្រាកដថា ពួកគាត់មិនរត់ចោលការងារ។ អ្នកជួញដូរធ្វើ ឲ្យប្រាកដថាជនរងគ្រោះជំពាក់ប្រាក់ខ្លួន។
- អ្នកជួញដូរដកយកឯកសារអត្តសញ្ញាណរបស់ជនចំណាកស្រុក ជាពិសេសលិខិតឆ្លងដែន។
- អ្នកជួញដូរកុហក់ថា យកជនចំណាកស្រុកទៅកន្លែងធ្វើការតាមគោលដៅ។

### ៥. តើគ្រឿងញៀនផ្តល់ទុក្ខទោសដល់មនុស្សក្នុងរូបភាពណាខ្លះ? (ពីម៉ោងសិក្សាទី ៦)

- វាអាចបង្ករការបំផ្លាញរយៈពេលវែងដល់រាងកាយ-ធ្វើទុក្ខបេះដូង សួត ថ្លើម និងតម្រងនោម។
- មនុស្សអាចលេបថ្នាំញៀនច្រើនហួសកម្រិត ដោយកំហុសឆ្គងហើយជាលទ្ធផល គឺស្លាប់។
- មនុស្សអាចនឹងឆ្លងមេរោគអេដស៍ និងជំងឺឆ្លងផ្សេងៗទៀតនៅពេលគេប្រើម្ជុលរួមគ្នាដើម្បីចាក់ថ្នាំញៀន។
- ថ្នាំញៀនអាចធ្វើឲ្យមនុស្សហ៊ានប្រថុយធ្វើអ្វីដែលមនុស្សធម្មតាគេមិនហ៊ានធ្វើ។

### ១៣. តើអ្វីខ្លះដែលអ្នកអាចគិតដល់នៅពេលអ្នកធ្វើសេចក្តីសម្រេចចិត្តដែរ?

- សិក្សាបន្ថែមអំពីប្រធានបទដែលអ្នកកំពុងគិតដល់?
- រៀបរាប់ពីជម្រើស។
- វាយតម្លៃលើហានិភ័យ និងអត្ថប្រយោជន៍ផ្សេងៗទៀត។

**១៥. រៀបរាប់អំពីវិធានការមួយចំនួនដែលអ្នកអាចធ្វើបានដើម្បីមានសុវត្ថិភាពពេលធ្វើដំណើរ?**

- បំពេញបញ្ជីត្រួតពិនិត្យរបស់អ្នកសិនមុននឹងចាកចេញ។
- ព្យាយាមយកឯកសារធ្វើដំណើរស្របច្បាប់ ដូចជាលិខិតឆ្លងដែន ឬទិដ្ឋាការការងារ មុនពេលអ្នកចាកចេញ ប្រសិនបើអាច។
- ទុកច្បាប់ថតចម្លងឯកសាររបស់អ្នកនៅផ្ទះរបស់អ្នក។ ប្រសិនបើអ្នកមានបញ្ហា ឬបាត់បង់ឯកសាររបស់អ្នក នោះឯកសារដែលអ្នកទុកអាចជួយអ្នកបាន។
- ធ្វើដំណើរដោយមានប្រាក់ជាប់ខ្លួនគ្រប់គ្រាន់ដើម្បីចំណាយលើការធ្វើដំណើរ ដើម្បីរស់នៅមួយរយៈពេលដែលគ្មានការងារធ្វើ និងដើម្បីត្រឡប់ទៅផ្ទះវិញ។
- រក្សាកូនសៀវភៅនាវិកវិររបស់អ្នក ឯកសារអត្តសញ្ញាណរបស់អ្នក និងប្រាក់នៅក្នុងកន្លែងលាក់កំបាំលាក់កំបាំងដែលមានសុវត្ថិភាព។
- ធ្វើដំណើរជាក្រុមជាមួយអ្នកចំណាកស្រុកផ្សេងទៀតដូចអ្នកដែរ (វាពិបាកក្នុងការបោកប្រាប្រាស់មនុស្សច្រើននាក់ក្នុងពេលតែមួយ ហើយជាក្រុមមានន័យថា អ្នកមានមិត្តដើម្បីជួយគ្នាបាន)។
- ត្រូវមានការសង្ស័យលើជនចម្លែកនៅក្នុងការធ្វើដំណើរចំណាកស្រុករបស់អ្នក (គេអាចជាអ្នកជួញដូរមនុស្ស)។
- ប្រសិនបើមាននរណាម្នាក់បង្ខំអ្នកឲ្យប្រគល់ឯកសារឲ្យគេ សុំឲ្យអ្នកដំណើរផ្សេងទៀតឬមន្ត្រីឲ្យជួយអ្នក។
- មិនត្រូវទៅតាមមនុស្សចម្លែក ដែលចូលមករកអ្នកក្នុងពេលកំពុងធ្វើដំណើរចំណាកស្រុកឡើយ។
- ព្យាយាមប្រើប្រាស់សេវាធ្វើដំណើរសាធារណៈ ជៀសវាងការជិះរថយន្តឯកជន ឬរថយន្តដឹកអ្នកដំណើរខ្នាតតូច។

**១២. តើលេខទូរស័ព្ទគ្រាអាសន្ននៅក្នុងប្រទេសគោលដៅនៅក្នុងប្រទេសរបស់អ្នកមានប៉ុន្មាន?**

- ចម្លើយសំណួរនេះគឺលេខទូរស័ព្ទដែលអ្នកបានបង្រៀនតាមរយៈកម្មវិធីសិក្សានេះ។

**១៣.តើលេខទូរស័ព្ទគ្រាអាសន្ននៅក្នុងប្រទេសគោលដៅនៅក្បែរប្រទេសរបស់អ្នកមានប៉ុន្មាន?**

- អ្នកចូលរួមអាចផ្តល់ឲ្យបាននូវលេខទូរស័ព្ទគ្រាអាសន្ន ឬលេខពីក្នុងតារាងដែលបានផ្តល់ឲ្យនៅលើ IS ២៥គ។

**១៤. តើលិខិតឆ្លងដែនគឺជាអ្វី?**

- លិខិតឆ្លងដែន គឺជាឯកសារចេញឲ្យដោយរដ្ឋាភិបាលនៃប្រទេសរបស់អ្នកដែល អនុញ្ញាតិឲ្យអ្នកអាចចេញ និងចូលប្រទេសរបស់អ្នកបាន។

**១៥. តើអ្វីជាទិដ្ឋាការ? (ពីមេរៀនទី ១២ និង ២៣)**

- ទិដ្ឋាកាគឺជាត្រា ឬក្រដាស់ស្អិតបិទនៅជាប់ក្នុងលិខិតឆ្លងដែនរបស់អ្នកដែលអនុញ្ញាតិឲ្យអ្នកចូលទៅក្នុងប្រទេសផ្សេងទៀតបាន។

**១៦. តើទិដ្ឋាការការងារ និងទិដ្ឋាការទេសចរណ៍ខុសគ្នាអ្វីខ្លះ? (ពីមេរៀនទី១២ និង២៣)**

- ទិដ្ឋាការការងារ អនុញ្ញាតិឲ្យអ្នកធ្វើការងារដោយស្របច្បាប់នៅក្នុងប្រទេសផ្សេង។ ទិដ្ឋការទេសចរណ៍ អនុញ្ញាតិឲ្យអ្នកដើរទស្សនាតែមួយមុខគត់ មិនអាចធ្វើការបានទេ។

**១៧. ប្រសិនបើអ្នកត្រូវធ្វើចំណាកស្រុក តើជំហានអ្វីខ្លះដែលអ្នកអាចធ្វើឲ្យការធ្វើចំណាកស្រុកនេះកាន់តែសុវត្ថិភាព។ តើអ្នកនឹងអនុវត្តជំហាននេះដែរឬទេ? ហេតុអ្វីធ្វើ? ឬហេតុអ្វីមិនធ្វើ?**

**១៨ . តើអ្នកបានចូលរួមក្នុងព្រឹត្តិការណ៍នៃសកម្មភាពសម្រាប់សហគមន៍ដែរ ឬទេ?**

- មិនមានចម្លើយត្រឹមត្រូវសម្រាប់សំណួរនេះទេ។ យើងសង្ឃឹមថាអ្នកចូលរួមនឹងអាចរៀបរាប់បានអំពីរបៀបដែលព្រឹត្តិការណ៍ទាំងនេះបានជួយដល់សហគមន៍របស់គេ។

**១៩. តើអ្នកគិតថា ព្រឹត្តិការណ៍ទាំងនេះនឹងជួយដល់សហគមន៍ដែរ ឬទេ? ប្រសិនបើជួយតើអ្នកអាចរៀបរាប់ពីរបៀបធ្វើបានដែរ ឬទេ?**

- មិនមានចម្លើយត្រឹមត្រូវសម្រាប់សំណួរនេះទេ។ យើងសង្ឃឹមថាអ្នកចូលរួមនឹងអាចរៀបរាប់បានអំពីរបៀបដែលព្រឹត្តិការណ៍ទាំងនេះបានជួយដល់សហគមន៍របស់គេ។ .

# IS ២៧ខ ÷ ទម្រង់យល់ព្រមលើសកម្មភាពសហគមន៍ ២៧

**អាន និងចុះហត្ថលេខាលើទំរង់យល់ព្រមសំរាប់សកម្មភាពសម្រាប់សហគមន៍ បន្ទាប់ពីឧបករណ៍នាវិកវៃឆ្លាតនេះត្រូវបានបញ្ចប់ ហើយមុនពេលធ្វើផែនការសម្រាប់ព្រឹត្តិការណ៍អំពីសកម្មភាពសហគមន៍។**

**ទម្រង់យល់ព្រមលើសកម្មភាពសហគមន៍**

កូនរបស់ខ្ញុំបានចូលរួមក្នុងព្រឹត្តិការណ៍សកម្មភាពសហគមន៍។ ខ្ញុំបានយល់ថា ខ្ញុំអាចដកកូនរបស់ខ្ញុំចេញបានគ្រប់ពេល ។

បាទ/ចាស ទេ

ឈ្មោះ ៖ ..............................

កាលបរិច្ឆេទ៖ ..............................

ហត្ថលេខា ៖..............................

ឈ្មោះរបស់កុមារ ៖..............................

ហត្ថលេខាកុមារ ៖..............................

# ២៨ មេរៀនទី២៨ ៖ សកម្មភាពសហគមន៍ - ជំហានទី ១

## វត្ថុបំណង

អ្នកចូលរួមនឹងពិភាក្សា និងពិចារណាអំពីបញ្ហានានាដែលបង្កើតឲ្យមានហានិភ័យពីអំពើជួញដូរដែលយុវជនជួបប្រទះនៅក្នុងសហគមន៍របស់គេ។

## ពេលវេលា

៧៥ នាទី

## សម្ភារៈ

- ស្ទីគ័រមួយកញ្ចប់ (ក្រដាសស្អិតបិទជាប់តូចៗ)
- ក្រដាសផ្ទាំងធំចំនួន ៣ សន្លឹកដែលមានបិទសញ្ញាថា "កើតឡើងញឹកញាប់" "កើតឡើងពេលខ្លះ" "កម្រកើតឡើង"
- ក្រដាសផ្ទាំងធំចំនួន ៣ សន្លឹកដែលមានបិទសញ្ញាថា "អាក្រក់" "អាក្រក់ខ្លាំង" "អាក្រក់បំផុតដែលអាចកើតមាន"
- រូបភាពពី "ТS ២៨ក ៖ ក្មេងប្រុសដែលជួបប្រទះបញ្ហាប្រឈម / ក្មេងស្រីដែលជួបប្រទះបញ្ហាប្រឈម" ថតចម្លងក្រដាសផ្ទាំងធំពីរសន្លឹក

## ការរៀបចំ

ប្រមូលយកនូវទម្រង់យល់ព្រម លើសកម្មភាពសហគមន៍មុនពេលចាប់ផ្តើមមេរៀនថ្មី។ នរណាដែលមិនបានចុះហត្ថលេខាលើទម្រង់ឯកភាពនេះ មិនអាចចូលរួមបានទេ រហូតទាល់តែគេបានធ្វើវា។

## សេចក្តីផ្តើម

**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចតៗគ្នានូវបញ្ជីចុះហត្ថលេខាវត្តមាន។

**សកម្មភាពមុនចាប់ផ្តើម**

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំល្បែងថាមពលនៅក្នុងតារាង។

**រំឭកមេរៀន**

តើលេខទូរស័ព្ទសម្រាប់គ្រាអាសន្ន ក្នុងប្រទេសរបស់អ្នកគឺមានលេខអ្វីខ្លះ? (ប្រសិនបើអ្នកចូលរួមច្រឡំ អនុវត្តឡើងវិញនូវដំណើរការកាលពីមេរៀនទី ២៥ ដែលក្រុមទាំងមូល បានផ្លាស់ប្តូរលេខជាមួយគ្នា)។

តើមាននរណាគិតថា តើអ្វីជាបញ្ហាប្រឈមធំបំផុតសម្រាប់សហគមន៍ពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដែរ ឬទេ? តើអ្នកអាចរៀបរាប់បានដែរ ឬទេ?

## សកម្មភាព

ពន្យល់ថា ប៉ុន្មានមេរៀនបន្ទាប់នឹងផ្តោតលើធ្វើការងារជាក្រុម ដើម្បីធ្វើសកម្មភាពជួយដល់សហគមន៍។ អ្នកចូលរួម នឹងកំណត់ឃើញពីអ្វីដែលគេចង់ធ្វើការកែល្អនៅក្នុងសហគមន៍របស់

គេ និងគិតអំពីវិធីដែលគេអាចធ្វើបានដើម្បីជួយដល់សមាជិក SNYC អាចធ្វើការងារជាមួយគ្នាបានល្អប្រសើរជាងមុន។

ការចូលរួមក្នុងគម្រោងនេះ គឺជាការស្ម័គ្រចិត្ត។ ធានាថា អ្នកគ្រប់គ្នាដែលចង់ចូលរួមក្នុងគម្រោងនេះ ត្រូវចុះហត្ថលេខាលើទម្រង់យល់ព្រមលើសកម្មភាពសហគមន៍ ។

ពន្យល់ប្រាប់ថា គម្រោងគួរមានការពាក់ព័ន្ធទៅនឹងជីវិតរបស់យុវជនដែលធ្វើសកម្មភាពនេះ។ ដូច្នេះមុនចាប់ផ្តើមគម្រោងសកម្មភាពសហគមន៍ គេគួរតែពិភាក្សាអំពីជីវិតរស់នៅរបស់យុវជននៅក្នុងសហគមន៍ជាមុនសិន។ ប្រាប់អ្នកចូលរួមថា មេរៀននេះនឹងចាប់ផ្តើមឡើងដោយការគូររូបដើម្បីជួយដល់គេក្នុងការគិតអំពីបញ្ហានេះ។ ចង្អុលទៅក្រដាសផ្ទាំងធំ ដែលនិយាយអំពី "ក្មេងប្រុសម្នាក់ដែលជួបប្រទះបញ្ហាប្រឈម / ក្មេងស្រីដែលជួបប្រទះបញ្ហាប្រឈម។

ចែកស្ទីគ័រជូនអ្នកចូលរួម។

ឲ្យអ្នកចូលរួមគិតអំពីបញ្ហាពិតប្រាកដដែលក្មេងប្រុស និងក្មេងស្រីនោះជួបប្រទះនៅក្នុងសហគមន៍របស់គេ។ ឲ្យគេសរសេរបញ្ហានៅលើក្រាសស្ទីគ័រ ដោយបញ្ហាមួយលើស្ទីគ័រមួយ ហើយបិទវាទៅលើក្រដាសផ្ទាំងធំត្រង់កន្លែងបញ្ហា។

(ឧទាហរណ៍នៃបញ្ហាមួយអាចជា "ក្មេងស្រីម្នាក់ជួបប្រទះបញ្ហាប្រឈម មិនអាចទៅសាលារៀនបានព្រោះនាងរំពឹងទុកថា នឹងត្រូវមើលថែប្អូនៗរបស់នាង ពេលឪពុកម្តាយរបស់នាងកំពុងធ្វើការងារ")

ឲ្យពួកគេគិតអំពីបញ្ហាខាងក្រោមម្តងមួយ ៖

- ការងារ
- ការអប់រំ
- ភាពក្រីក្រ
- រងទុក្ខទោសលើរាងកាយ
- អ្វីដែលកើតឡើងចំពោះគេពេលនេះដែលអាចមានផលប៉ះពាល់អាក្រក់ដល់អនាគតរបស់គេ។

នៅពេលដែលស្ទីគ័រទាំងអស់ត្រូវបានបិទលើរូបភាពអស់ហើយនោះ សូមអានឲ្យឮៗ។

## ស្ទីគ័រជាក្រុម

បន្ទាប់មក ឲ្យអ្នកចូលរួមបកស្ទីគ័រចេញ ហើយព្យាយាមប្រមូលផ្តុំបញ្ហានៅលើក្រដាសផ្ទាំងធំចំនួន ៣សន្លឹកដែលមានបិទសញ្ញាថា "កើតឡើងញឹកញាប់" "កើតឡើងពេលខ្លះ" "កម្រកើតឡើង"។ លើកទឹកចិត្តឲ្យមានការពិភាក្សាក្នុងចំណោមអ្នកចូលរួម អំឡុងពេលគេកំពុងរៀបប្រភេទ បញ្ហានៅលើក្រដាសផ្ទាំងធំ។ បន្ទាប់មកសុំឲ្យអ្នកចូលរួមរៀបប្រភេទស្រាយបញ្ហានៅលើក្រដាសផ្ទាំងធំទាំងបីសន្លឹកដែលមានបិទសញ្ញាថា "អាក្រក់" "អាក្រក់ខ្លាំង" "អាក្រក់បំផុតដែលអាចកើតមាន"។ លើកទឹកចិត្តឲ្យមានការពិភាក្សាក្នុងចំណោមអ្នកចូលរួម អំឡុងពេលគេកំពុងរៀបប្រភេទបញ្ហា។

បន្ទាប់មក អ្នកសម្របសម្រួល សួរទៅអ្នកចូលរួម អំពីបញ្ហាដែលអាចពាក់ព័ន្ធទៅនឹង ការធ្វើចំណាកស្រុកដែលមិនមានសុវត្ថិភាព និងការជួញដូរមនុស្ស។ ប្រសិនបើអ្នកចូលរួម មិនអាចឆ្លើយបានអ្នកសម្របសម្រួលត្រូវពន្យល់ពីការភ្ជាប់ណាមួយ។ ឧទាហរណ៍ថា "ក្មេងស្រីម្នាក់ដែលមិនបានទៅរៀនមិនចេះសរសេរអក្សរ មិនអាចអាន កិច្ចសន្យាការងារ បានដើម្បីដឹងថាតើអ្វីដែលនាងនឹងចុះហត្ថលេខានោះមានលក្ខណៈស្មើភាពដែរ ឬយ៉ាងណានោះទេ" ។

**សង្ខេបមេរៀន**

ពិនិត្យឡើងវិញលើបញ្ហាពិតប្រាកដដែល ក្មេងប្រុស និងក្មេងស្រីនៅក្នុងសហគមន៍នោះ បានលើកឡើងនៅក្នុងផ្នែកនិយាយពីបញ្ហា។

អ្នកសម្របសម្រួលគួរសង្ខេបពីលទ្ធផលនៃតារាងរៀបរាប់អំពីយុវជន។ អ្នកសម្របសម្រួលគួរនិយាយថា "មានបញ្ហាបីប្រភេទ ភ្ជាប់ទំនាក់ទំនងទៅនឹងការជួញដូរមនុស្ស នៅក្នុងសហគមន៍របស់ យើង រួមមាន ..."

"មានបញ្ហាបីប្រភេទដែលអាក្រក់បំផុតដែលភ្ជាប់ទំនាក់ទំនងទៅនឹងការជួញដូរមនុស្សនៅក្នុងសហគមន៍របស់យើង រួមមាន ..."

**ការបិទបញ្ចប់**

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានមកចូលរួម។ បញ្ជាក់ឡើងវិញពីការប្រជុំក្លិប ពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមមេរៀននេះ។ ឲ្យអ្នកចូលរួម ចំណាយពេលវេលាខ្លះមុនមេរៀនបន្ទាប់ ឲ្យគិតអំពីថា តើបញ្ហាប្រឈមអ្វីខ្លះដល់យុវជននៅក្នុងសហគមន៍ដែលគេគិតថា មានសារៈសំខាន់ដើម្បីដោះស្រាយ។ អ្នកសម្របសម្រួលអាចឲ្យអ្នកចូលរួម សរសេររាល់ចំណុចនេះនៅលើក្រដាសដើម្បីយកទៅផ្ទះ គ្រាន់ជួយរំឭកកុំឲ្យភ្លេច។





# មេរៀនទី២៩ ÷ ការចែករំលែកអ្វីដែលអ្នកចេះជាមួយអ្នកដទៃ ២៩

**ចំណុចបំណង**

អ្នកចូលរួមនឹង សម្រេចចិត្តលើបញ្ហាមួយនៅក្នុងសហគមន៍របស់គេដែលត្រូវដោះស្រាយ ហើយនឹង ណែនាំឲ្យស្គាល់ពីឧទាហរណ៍ផ្សេងទៀតដែលត្រូវធ្វើសកម្មភាព។

**ពេលវេលា**

៧៥ នាទី

**សេចក្តីផ្តើម**

**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចតៗគ្នានូវបញ្ជីចុះហត្ថលេខាវត្តមាន។

**សកម្មភាពមុនចាប់ផ្តើម**

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំល្បែងថាមពលនៅក្នុងតារាង។

**សម្ភារៈ**

- ស្ទីគ័រ
- ក្រដាសផ្ទាំងធំមួយសន្លឹកដែលមានសរសេរ "ធ្ងន់ធ្ងរបំផុត" នៅផ្នែកខាងលើ និងក្រដាសមួយផ្ទាំងទៀតមានសរសេរ "សាមញ្ញ បំផុត" នៅផ្នែកខាងលើ
- ក្រដាសផ្ទាំងធំទំនេរមួយ
- ប៊ិច
- ថតចម្លងពី ៥-៨ ច្បាប់នូវ "IS ២៩ក ៖ ដើមឈើតាងបញ្ហា"
- "IS ២៩ក ៖ ឧទាហរណ៍នៃ ដើមឈើតាងបញ្ហា" សម្រាប់ជាឯកសារយោងរបស់អ្នកសម្របសម្រួល។

**រំឭកមេរៀន**

តើលេខទូរស័ព្ទសម្រាប់គ្រាអាសន្នក្នុងប្រទេសរបស់អ្នកគឺអ្វីខ្លះ? (ប្រសិនបើអ្នកចូលរួមច្រឡំ អនុវត្តឡើងវិញ នូវដំណើរការកាលពីមេរៀនទី ២៥ ដែលក្រុមទាំងមូល បានផ្លាស់ប្តូរលេខជាមួយគ្នា)។

តើមាននរណាម្នាក់គិតថា តើអ្វីជាបញ្ហាប្រឈមធំបំផុតសម្រាប់យុវជនក្នុងសហគមន៍ដែរ ឬទេ? ហេតុអ្វីបានជាបញ្ហានេះមានសារៈសំខាន់?

## ការណែនាំអំពីដើមឈើបញ្ហា

ឲ្យអ្នកចូលរួមត្រឡប់ក្រោយទៅមេរៀនមុន នៅពេលដែលគេនិយាយអំពីការធ្វើគម្រោងនានាដើម្បីជួយដល់សហគមន៍។ មេរៀននេះចាប់ផ្តើមដោយការនិយាយអំពីបញ្ហាដែលពាក់ព័ន្ធនឹងការធ្វើចំណាកស្រុក និងការជួញដូរ។ ឲ្យអ្នកចូលរួមសរសេរលើស្ទីគ័រអំពីបញ្ហាដែលគេគិតថាមានភាពធ្ងន់ធ្ងរបំផុត។ បន្ទាប់មក ឲ្យគេសរសេរស្ទីគ័រផ្សេងៗគ្នានូវបញ្ហាដែលគេគិតថាមានភាពសាមញ្ញបំផុត។

បន្ទាប់មកទៀត ឲ្យអ្នកចូលរួមបិទបញ្ហាដែលគេគិតថា មានពាក់ព័ន្ធនឹងភាពសាមញ្ញបំផុត។ បន្ទាប់មកទៀតឲ្យអ្នកចូលរួមបិទបញ្ហាពីរទៅលើក្រដាសផ្ទាំងធំមួយដែលមានសរសេរចំណងជើងថា "ធ្ងន់ធ្ងរបំផុត" ឬបិទលើក្រដាសដែលមានសម្គាល់ថា "សាមញ្ញបំផុត"។

ពន្យល់ថា ជំហានបន្ទាប់នឹងនិយាយអំពីបញ្ហាទាំងនេះដោយប្រើប្រាស់ "ដើមឈើតាងបញ្ហា"។

- សរសេរសៀវភៅ។
- បង្រៀននៅសាលារៀនអំពីលេខទូរស័ព្ទសម្រាប់គ្រាអាសន្ន។
- ធ្វើយុទ្ធនាការផ្សព្វផ្សាយតាមបណ្ដាញអ៊ិនធឺណិតតាមរយៈហ្វេសប៊ុក ដើម្បីចែករំលែកលេខទូរស័ព្ទសម្រាប់គ្រាអាសន្ន។

សុំឲ្យក្រុមបង្ហាញពីបញ្ហា និងគំរោងរបស់គេ។

ឲ្យក្រុមទាំងអស់ពិភាក្សាពីដំណោះស្រាយណាដែលអាចធ្វើបាន និងដំណោះស្រាយណាខ្លះដែលលំបាកខ្លាំងក្នុងការបង្ហាញ។ (ក្រុមត្រូវជ្រើសរើសដំណោះស្រាយមួយដែលអាចសម្រេចបាននៅក្នុងមេរៀនទាំងបួន ហើយដែលវាមិនពិបាក)។

ចុងក្រោយ ឲ្យអ្នកចូលរួមបោះឆ្នោតសម្រាប់គំរោងណាដែលគេចង់ធ្វើនៅក្នុងក្រុម។

### កំណត់ហេតុ

ឲ្យអ្នកចូលរួមសរសេរអំពីមធ្យោបាយដែលគេអាចជួយដល់សហគមន៍របស់គេ។

### សង្ខេបមេរៀន

- យើងនឹងធ្វើសកម្មភាពសហគមន៍សម្រាប់ប៉ុន្មានមេរៀនបន្ទាប់ទៀត។
- សកម្មភាពសហគមន៍ គួតែ (បញ្ចូលគំរោងដែលគេបានបោះឆ្នោតជ្រើសយក)។ ________ ____________________________________________

### ការបិទវគ្គ

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ ឬ ផ្ដល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានមកចូលរួម។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លិបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងមេរៀននេះ។




សេពគ្រឿងស្រវឹង
មានកូនសំណាងមិនល្អ
លែងលះគ្នា
មិនអាចធ្វើការបានល្អ
មានជម្លោះក្នុងគ្រួសារ
ញៀនថ្នាំ
សុខភាពមិនល្អ
ភាពក្រីក្រ
ខ្វះខាតប្រាក់ /ពេលវេលា
ការវាយតប់
ជំពាក់បំណុលគេ
បញ្ហាសង្គម
សុខភាពផ្លូវចិត្ត
ត្រូវបាននគរបាលចាប់
បញ្ហាផ្លូវចិត្ត
ទំនៀមទម្លាប់វប្បធម៌
តម្លៃថោក ងាយស្រួលទិញ
សម្ពាធពីមិត្តភក្តិ
អនុវត្តអាកប្បកិរិយា "មនុស្សធំ"
ការរាប់អានមិត្តភក្តិ
ចង់សម្រាក
បំបាត់ភាពតប់ប្រមល់



## IS មេរៀនទី៣០ ៖ សកម្មភាពសហគមន៍ជំហានទី៣ ៣០

### វត្ថុបំណង
អ្នកចូលរួមនឹងបង្កើតផែនការសកម្មភាពសហគមន៍របស់គេ។

### ពេលវេលា
៧៥ នាទី

**សម្ភារៈ**
- ក្រដាសផ្ទាំងធំ និងប៊ិច
- ថតចម្លងមួយច្បាប់នូវ "IS ៣០ក ៖ ផែនការសកម្មភាពសម្រាប់សហគមន៍" នៅលើក្រដាសផ្ទាំងធំមួយផ្ទាំង

### សេចក្ដីផ្ដើម
**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចតៗគ្នានូវបញ្ជីចុះហត្ថលេខាវត្តមាន។

**សកម្មភាពមុនចាប់ផ្ដើម**

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំសកម្មភាពចាប់ផ្ដើមមុននៅក្នុងតារាង។

**រំឭកមេរៀន**

តើលេខទូរស័ព្ទសម្រាប់គ្រាអាសន្នប្រទេសរបស់អ្នកគឺអ្វីខ្លះ? (ប្រសិនបើអ្នកចូលរួមច្រឡំអោយពួកគេអនុវត្តឡើងវិញនូវដំណើរការដែលក្រុមទាំងមូលបាន សូត្រលេខទូរស័ព្ទទាំងអស់គ្នា)។

ឲ្យអ្នកចូលរួមស្ម័គ្រចិត្តរំឭកឡើងវិញសកម្មភាពសហគមន៍ដែលពួកគេបានសម្រេចចិត្តជ្រើសរើស និងរបៀបដែលគេបានសម្រេចចិត្តក្នុងពេលនោះ។

### សកម្មភាព
ពន្យល់ថា ថ្ងៃនេះអ្នកចូលរួមនឹងត្រូវរៀបចំផែនការអំពីសកម្មភាពសហគមន៍របស់គេ។ មេរៀនអំពីការរៀបចំផែនការនេះ នឹងជួយដល់ពួកគេក្នុងការធ្វើផែនការសម្រាប់ព្រឹត្តិការណ៍នេះ ប៉ុន្តែវាក៏ជួយ ពួកគេឲ្យរៀបចំផែនការសម្រាប់ជីវិតរបស់គេបានផងដែរ។

ពន្យល់ថា ចំណុចដំបូងដែលគេត្រូវធ្វើនោះ គឺការកំណត់គោលដៅ។ គោលដៅគឺពន្យល់ពីសកម្មភាពសហគមន៍ដែលត្រូវធ្វើ។

មុននឹងចាប់ផ្ដើមកំណត់គោលដៅ ត្រូវសួរទៅអ្នកចូលរួមថា "តើយើងនឹងត្រូវធ្វើអ្វី?"

សរសេរចម្លើយរបស់អ្នកចូលរួម នៅលើក្រដាសផ្ទាំងធំ។ បន្ទាប់មកជួយអ្នកចូលរួមឲ្យធ្វើកិច្ចការនេះ ដោយបង្កើតពាក្យពេចន៍អោយចេញជាប្រយោគគោលដៅមួយ។ សរសេរប្រយោគនោះនៅពីក្រោមពាក្យថា "គោលដៅ" នៅលើក្រដាសផ្ទាំងធំដែលមានសរសេរផែនការសកម្មភាពសហគមន៍ (ថតចម្លង "IS ៣០ក៖ ផែនការអំពី សកម្មភាពសម្រាប់ សហគមន៍")។

ពន្យល់ថា កិច្ចការបន្ទាប់ទៀត ក្រុមនឹងធ្វើការសម្រេចចិត្តលើ សកម្មភាពរបស់ពួកគេ។ សកម្មភាពគឺជាធាតុតូចៗដែលក្រុមត្រូវធ្វើដើម្បីឲ្យសម្រេចបានដល់គោលដៅ ។

សួរអ្នកចូលរួមថា "តើជំហានតូចៗអ្វីខ្លះដែលយើងត្រូវធ្វើដើម្បីឲ្យសម្រេចបាននូវគោលដៅរបស់យើង?"

សរសេរចម្លើយរបស់អ្នកចូលរួមនៅខាក្រោម "សកម្មភាព" ។
ពន្យល់ថា ពេលនេះគេត្រូវគិតអំពីសម្ភារដែលត្រូវប្រើ។ សម្ភារដែលត្រូវប្រើគឺជាវត្ថុដែលអ្នកចូលរួមត្រូវការដើម្បីមានលទ្ធភាពអាចធ្វើសកម្មភាពបាន (ឧទាហរណ៍ដូចជា ក្រដាស ប៊ិច)។
សួរថា "តើសំភារៈអ្វីខ្លះដែលយើងត្រូវការដើម្បីធ្វើសកម្មភាពនីមួយៗ?"
សរសេរចម្លើយរបស់អ្នកចូលរួមពីក្រោម "សម្ភារៈដែលត្រូវការ"។
សួរថា "តើនរណាជាអ្នកធ្វើសកម្មភាពនីមួយៗ?"
សរសេរឈ្មោះអ្នកស្ម័គ្រចិត្តសម្រាប់សកម្មភាពនីមួយៗ នៅក្នុងតារាង "អ្នកដែលធ្វើសកម្មភាព"។
ចុងក្រោយ ពួកគេត្រូវតែសម្រេចចិត្តថា តើសកម្មភាពនីមួយៗត្រូវបំពេញនៅពេលណា។
ពន្យល់ថា ក្លឹបយុវវ័យ SNYC អាចជួបគ្នាម្តង ឬពីរដងទៀតដើម្បីរៀបសកម្មភាពសហគមន៍។ នេះមានន័យថា ពួកគេមានពេលសរុប2-3ម៉ោងប៉ុណ្ណោះដើម្បីធ្វើការលើសកម្មភាពសហគមន៍របស់គេ។
ពន្យល់ថា អ្នកចូលរួមក៏អាចធ្វើកិច្ចការ និងរៀបចំកាលវិភាគសម្រាប់ព្រឹត្តិការណ៍នៅក្រៅម៉ោងប្រជុំក្លិបបានផងដែរ ប្រសិនបើទៅរួច និងធ្វើទៅតាមកាលវិភាពរបស់ពួកគេ។
ឲ្យអ្នកចូលរួមសរសេរកាលបរិច្ឆេទសម្រាប់កិច្ចការផ្សេងៗគ្នានៅក្នុងផែនការរបស់គេ នៅពីក្រោមចំណុច "ថ្ងៃខែឆ្នាំ ដែលត្រូវបំពេញ" ។

**សង្ខេបមេរៀន**

- ពិនិត្យឡើងវិញលើផែនការនីមួយៗដើម្បីឲ្យប្រាកដថា អ្នកចូលរួមម្នាក់ៗដឹងច្បាស់អំពីអ្វីដែលគេទទួលខុសត្រូវសម្ភារៈប្រើប្រាស់ដែលគេត្រូវធ្វើ និងដឹងអំពីពេលវេលា ដែលត្រូវធ្វើវា។

## ការបិទបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ ឬផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។
អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានមកចូលរួម។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លិបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងមេរៀននេះ។
សួរថា តើមានអ្នកចូលរួមណាដែលនឹងត្រូវការជំនួយបន្ថែមក្នុងការបំពេញសកម្មភាពរបស់គេដែរ ឬទេ។ ប្រសិនបើមាន សួរគេឲ្យរងចាំ ៥ នាទីពេលចប់ម៉ោងដើម្បីពិភាក្សាអំពីបញ្ហានេះ។
ប្រសិនបើអ្នកចូលរួមនឹងត្រូវបំពេញសកម្មភាពរបស់ខ្លួននៅក្រៅម៉ោងសិក្សា ឲ្យគេសរសេរសកម្មភាពទាំងនេះនៅលើក្រដាស មួយសន្លឹកដើម្បីយកទៅផ្ទះទុករំឭកកុំឲ្យគេភ្លេច។

| គោលដៅ | សកម្មភាព | សម្ភារៈត្រូវការ | អ្នកទទួលខុសត្រូវ | ថ្ងៃ ខែ ឆ្នាំធ្វើសកម្មភាព |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

# ៣១ មេរៀនទី៣១ ៖ សកម្មភាពសហគមន៍-ជំហានទី ៤

## ទិន្នផល

អ្នកចូលរួមអនុវត្តព្រឹត្តិការណ៍ស្តីពីសកម្មភាពសហគមន៍របស់គេ។

## ពេលវេលា

៧៥ នាទី

## សម្ភារៈ

- សម្ភារៈដែលមានរៀបរាប់នៅក្នុងតារាងខាងក្រោមគឺ សម្ភារៈត្រូវការនៅក្នុងផែនការសកម្មភាព សហគមន៍ដែលអ្នកចូលរួមបានបំពេញកាលពីមេរៀនមុន។
- "IS ៣១ ៖ គំរូវិញ្ញាបនបត្របញ្ចប់ការសិក្សា"

## ការរៀបចំត្រៀម

ជួបជាមួយអ្នកចូលរួមនៅមុនពេលចាប់ផ្តើមព្រឹត្តិការណ៍អំពីសកម្មភាពសម្រាប់សហគមន៍។ ពិនិត្យឡើងវិញ លើផែនការនីមួយៗដើម្បីឲ្យប្រាកដថា អ្នកចូលរួមម្នាក់ៗដឹងច្បាស់អំពីអ្វីដែលគេទទួលខុសត្រូវធ្វើ មានសម្ភារប្រើប្រាស់ដែលគេត្រូវមានដើម្បីធ្វើកិច្ចការនេះ និងដឹងអំពីពេលវេលាច្បាស់លាស់ដើម្បីធ្វើកិច្ចការនេះ

## សកម្មភាព

SNYC ត្រូវអនុវត្តព្រឹត្តិការណ៍អំពីសកម្មភាពសម្រាប់សហគមន៍។ ធ្វើឲ្យប្រាកដថា អ្នកបានជជែកជាមួយអ្នកចូលរួមនៅពេលដែលព្រឹត្តិការណ៍ត្រូវបានបញ្ចប់ ហើយថ្លែងអំណរគុណដល់អ្នកចូលរួមសម្រាប់កិច្ចការរបស់គេ។ ព្រឹត្តិការណ៍អំពីសកម្មភាពសម្រាប់សហគមន៍នេះ ត្រូវបានរៀបចំតាក់តែងឡើងដើម្បីកសាងជំនាញ និងការគោរពខ្លួនឯងរបស់អ្នកចូលរួម។ ចំណុចនេះមានសារៈសំខាន់ស្មើនឹងលទ្ធផលនៃព្រឹត្តិការណ៍នេះ។ ដូច្នេះត្រូវកុំភ្លេចសម្តែងការអបអរសាទរដល់អ្នកចូលរួម។

រៀបចំពិធីជុបលៀងមួយដើម្បីរៀបចំបិទវគ្គសិក្សាអំពី ឧបករណ៍នាវិកវៃឆ្លាតនេះ និងដើម្បីចែកនូវផ្កាយ និងរង្វាន់លើកទឹកចិត្ត។ អ្នកសម្របសម្រួលជាមនុស្សធំរបស់ SNYC គួរចែកជូនផ្ទាល់ដៃនូវវិញ្ញាបនបត្រជូនដល់អ្នកចូលរួម។ ពិធីជប់លៀងបញ្ចប់វគ្គសិក្សានេះ ត្រូវរាប់បញ្ចូលអ្នកចូលរួមដែលមិនបានជ្រើសរើសចូលរួម ក្នុងព្រឹត្តិការណ៍អំពីសកម្មភាព សម្រាប់សហគមន៍ដូចជាអ្នកដែលបានចូលរួមផងដែរ។ ត្រូវធានាថា អ្នកបានចែកជូននូវផ្កាយ និងរង្វាន់លើកទឹកចិត្តក្នុងលក្ខណៈមួយដែលមិនធ្វើឲ្យអ្នកដែលមិនបានទទួល មានអារម្មណ៍អាក់អន់ស្រពន់ចិត្តឡើយ។ ស្របពេលជាមួយគ្នាដែរ ត្រូវប្រាកដថា បានប្រគល់នូវរង្វាន់លើកទឹកចិត្ត ឬការទទួលស្គាល់ជាពិសេសជូនចំពោះអ្នកដែលបានមករៀនរាល់មេរៀន និង/ឬ អ្នកដែលមករៀនទៀងទាត់បានល្អ។ ប្រារព្ធធ្វើជាមួយអ្នកចូលរួមរបស់អ្នក។

World Vision®

# វិញ្ញាបនបត្របញ្ចប់វគ្គបណ្តុះបណ្តាល

សូមបញ្ជាក់ថា

បានបញ្ចប់ដោយជោគជ័យនូវវគ្គបណ្តុះបណ្តាលស្តីពី

## ឧបករណ៍នាវិកវៃឆ្លាត

រៀបចំឡើងនៅ ______________________ ថ្ងៃទី ______________________

ទីកន្លែង កាលបរិច្ឆេទ

**អ្នកសម្របសម្រួលក្លឹបយុវជននាវិកវៃឆ្លាត**

ហត្ថលេខា ______________________

**បុគ្គលិក ETIP អង្គការ ទស្សនៈពិភពលោក**

ហត្ថលេខា ______________________

# កំណត់ចំណាំ

សូមប្រើទំព័រនេះដើម្បីសរសេរការកត់ចំណាំអ្វីផ្សេងៗដែលអ្នកចង់ចងចាំទុកនៅពេលដែលអ្នកត្រឡប់ទៅកាន់សហគមន៍របស់អ្នកវិញ។